00757408

E131/18

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីជូនដំណឹងអំពីការកែប្រែលំដាប់លំដោយនៃការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីសម្រាប់សវនាការជំណាក់កាលដំបូង (ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ០៥ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) និងព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសវនាការពិនិត្យភស្តុតាងក្នុងអំឡុងសវនាការខាងលើ (ឯកសារ E131/1.2)

យោងឧបសម្ព័ន្ធ ខ សម្ងាត់ (ឯកសារ E131/1.2) ដែលបានជូនដំណឹងជាមុនទៅភាគីស្តីពីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីចំនួន ៨ រូប ដែលអង្គជំនុំជម្រះនឹងកោះហៅឱ្យចូលសវនាការនៅថ្ងៃខាងលើ និងថ្ងៃបន្តបន្ទាប់។ អនុស្សរណៈនេះមានគោលបំណងជូនដំណឹងថា អង្គជំនុំជម្រះមានបំណងកែប្រែលំដាប់លំដោយនៃការកោះហៅសាក្សីដូចតាមការបញ្ជាក់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ខាងលើ និងផ្តល់ព័ត៌មានថ្មីៗទៅភាគីពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដំបូងនៃសំណុំរឿង ០០២/០១៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 12 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

*ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖*

ថ្វីបើអង្គជំនុំជម្រះនៅមានបំណងស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាមសម្គាល់ TCCP 185 និង TCCCP 123 (ទៅតាមលំដាប់លំដោយ និងភ្លាមៗបន្ទាប់ពីការសួរសំណួរទៅជនជាប់ចោទ) ក្តី ក៏អង្គជំនុំជម្រះទើបបានដឹងអំពីបញ្ហាកំហិតផ្នែកបច្ចេកទេសដែលអាចបង្អាក់មិនឲ្យខ្លួនមានលទ្ធភាពស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះដូចតាមការគ្រោងទុក។ អង្គជំនុំជម្រះនឹងសម្រេចជាស្ថាពរលើបញ្ហានេះនៅល្ងាចថ្ងៃ ច័ន្ទ ទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១។ អាស្រ័យហេតុនេះ សូមភាគីជ្រាបថា អង្គជំនុំជម្រះអាចនឹងងាកទៅស្តាប់សក្ខីកម្មសាក្សីខាងក្រោមផ្ទាល់តែម្តងក្រោយពីចប់ការសួរសំណួរទៅជនជាប់ចោទ។

អង្គជំនុំជម្រះសូមប្រកាសថា នៅសវនាការជំណាក់កាលដំបូងនេះ អង្គជំនុំជម្រះនឹងមិនស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP 142 ឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនឹងត្រូវផ្តល់សក្ខីកម្មនៅជំណាក់កាលបន្ទាប់។

*ការស្តាប់សក្ខីកម្មរបស់សាក្សី៖*

អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគី អំពីការកែប្រែលំដាប់លំដោយនៃការកោះហៅសាក្សី ដែលមានរាយនាមនៅក្នុងឧបសម្ព័ន្ធ ខ សម្ងាត់ ដោយអង្គជំនុំជម្រះសម្រេចកោះហៅសាក្សីតាមលំដាប់លំដោយដូចខាងក្រោមវិញ៖

សាក្សីដែលមានរហស្សនាម៖
TCW 542
TCW 395
TCW 564
TCW 583

សាក្សីដែលមានរហស្សនាម TCW 395 ជាមនុស្សចាស់ដែលមានសុខភាពអន់ខ្សោយខ្លាំង រស់នៅតំបន់ដាច់ស្រយាល និងគ្មានសម្បទាគ្រប់គ្រាន់នឹងធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ។ អង្គជំនុំជម្រះបានសម្រេចស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះតាមប្រព័ន្ធសោតទស្សន៍។ តម្រូវការផ្នែកបច្ចេកទេសក្នុងការបង្កើតទំនាក់ទំនងតាមប្រព័ន្ធសោតទស្សន៍ ទាមទារនូវការងារច្រើន។ ដោយហេតុថា សាក្សីរូប

E131/18

នេះមានសុខភាពមិននឹងនរពីមួយថ្ងៃទៅមួយថ្ងៃ ទើបអង្គជំនុំជម្រះអាចត្រូវស្តាប់សក្ខីកម្មសាក្សីរូបនេះឱ្យបានមុនពេលកំណត់ ឬក្រោយពេលកំណត់ អាស្រ័យតាមការចាំបាច់។

ថ្វីត្បិតសាក្សីដែលមានរហស្សនាម TCW 564 និង TCW 583 អាចនឹងមិនទាន់ត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្ម រហូតដល់អង្គជំនុំជម្រះសាលាដំបូងបន្តធ្វើសវនាការនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១១ ក្តី ក៏សាក្សីទាំងនេះត្រូវបានកោះនៅដំណាក់កាលនេះ ដើម្បីត្រៀមខ្លួននៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសវនាការពីថ្ងៃទី ០៥ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១។

ដោយអនុលោមតាមសំណើ E144 របស់សហព្រះរាជអាជ្ញា នៅថ្ងៃនេះ អង្គជំនុំជម្រះបានស្នើទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញសុំឱ្យពិនិត្យបន្ថែមទៅលើរបាយការណ៍ពាក់ព័ន្ធនឹងសាក្សីដែលនៅសេសសល់ចុងក្រោយនៅក្នុងឧបសម្ព័ន្ធ ខ សម្ងាត់ (សាក្សីដែលមានរហស្សនាម TCW 297) និងជូនដំណឹងមកអង្គជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន (ឯកសារ E144/1)។